# របាយការណ៍សង្ខេបកិច្ចប្រជុំក្រុមប្រឹក្សាពិគ្រោះយោបល់
# ស្តីពីការងារយុវជន និងជំងឺអេដស៍នៅកម្ពុជា

នាថ្ងៃទី ម្ភៃ ខែ មិថុនា ឆ្នាំ ពីរពាន់ដប់បួន នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មានកិច្ចប្រជុំក្រុមការងារប្រឹក្សាពិគ្រោះយោបល់ស្តីពីការងារយុវជន និង បញ្ហាមេរោគអេដស៍នៅកម្ពុជា។ សមាភាពចូលរួមមានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្រសួងអប់រំ យុវជន និងកីឡា អង្គការយុវជន និងអង្គការ ធ្វើការងារកម្មវិធីមេរោគអេដស៍ បណ្តាញអ្នកងាយរងគ្រោះដោយសារមេរោគអេដស៍ និងជំងឺអេដស៍ និងយុវជនងាយរងគ្រោះផ្ទាល់ប្រមាណជា ម្ភៃប្រាំនាក់។

***គោលបំណងសំខាន់ៗនៃកិច្ចប្រជុំរួមមាន:***

- ពិនិត្យលើការអនុវត្តការងារផ្នែកយុវជន ជាពិសេសយុវជនងាយរងគ្រោះដោយសារជំងឺអេដស៍ ទាក់ទងនឹងបញ្ហាមេរោគអេដស៍ និងជំងឺអេដស៍ និងឥរិយាបទប្រឈមរបស់ពួកគេ
- ផ្តោតលើគោលនយោបាយថ្មីរបស់រដ្ឋាភិបាលអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បានផ្តួចផ្តើមនូវការចងក្រងឯកសារគោល Concept Note ផ្នែកយុវជន ដើម្បីប្រើប្រាស់នៅកម្ពុជា
- ពិនិត្យ និងពិភាក្សានៃដំណើរការចងក្រង មាតិការបស់ឯកសារ និងដាក់បញ្ចូលចំណុចសំខាន់ៗ ដើម្បីឱ្យឯកសារមានន័យ និងខ្លឹមសារគ្រប់គ្រាន់
- ពិភាក្សារួមក្នុងកំណត់យុទ្ធសាស្រ្ត និងសកម្មភាពលើ ដើម្បីដាក់បញ្ចូលបន្ថែមលើឯកសារគោល និងវគ្គបណ្តុះបណ្តាល

***លទ្ធផលនៃកិច្ចប្រជុំ***

***១. ឯ.ឧ វេជ្ជបណ្ឌិត តែង គន្ធី*** បានបញ្ជាក់ពីចំណុចសំខាន់ៗ នៃកិច្ចប្រជុំនេះ ថាការចងក្រងឯកសារគោល ស្តីពីយុវជនងាយរងគ្រោះនេះថា ដោយផ្អែកលើគោលនយោបាយថ្មីរបស់រដ្ឋាភិបាលកម្ពុជា ក្នុងការប្រយុទ្ធប្រឆាំងការរាលដាលមេរោគអេដស៍ នៅកម្ពុជា។ ជាងនេះទៀត គឺជួយបំពេញបន្ថែមដល់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការផ្សព្វផ្សាយបន្ថែមការដល់យុវជនដែលស្ថិតនៅក្រៅសាលា ។

*២. ការចងក្រងឯកសារគោលស្តីពីយុវជនងាយរងគ្រោះដោយសារមេរោគអេដស៍(ជំនួយថវិកា Youth LEAD)៖*តាមរយៈការសក្សាស្រាវជ្រាវ របស់ក្រសួងអប់រំ យុវជន និងកីឡា ចំពោះយុវជនងាយរងគ្រោះ បានបង្ហាញថា ក្រុមនេះ បានជួបនូវបញ្ហាជាច្រើន ដូចជាការប្រឈមការឆ្លងមេរោគអេដស៍ ការមិនទទួលបានព័ត៌មានមេរោគអេដស៍ សុខភាពផ្លូវភេទនិងសុខភាពបន្តពូជ ការមិនបានទៅទទួលសេវាតេស្តឈាម ការពិនិត្យ និងព្យាបាលកាមរោគ ការមាផ្ទៃពោះ និងការរំលូតកូន។ ដូចនេះ ដើម្បីបំពេញទៅនឹងតម្រូវការក៏ដូចជាដោះស្រាយបញ្ហាទាំងអស់នេះ និងជួយគាំទ្រដល់គោលនយោបាយថ្មី ឯកសារគោលនេះ ត្រូវបានរៀបចំតាក់តែងឡើងក្នុងគោលបំណងសំខាន់ គឺ ដើម្បីកាត់បន្ថយការរីករាលដាលមេរោគអេដស៍ក្នុងចំណោមយុវជនងាយរងគ្រោះ***(យុវជនបុរសស្រឡាញ់បុរស យុវជនស្រីស្រស់ យុវតីបម្រើការកន្លែងកម្សាន្ត និងយុវជនប្រើប្រាស់គ្រឿងញៀន)*** ដែលមានអាយុចន្លោះពី ១៥ ទៅ ៣០ ឆ្នាំ ។ គោលបំណងជាក់លាក់ដូចជា:

- កំណត់ពីតម្រូវការជាក់លាក់របស់យុវជនងាយរងគ្រោះ ដើម្បីដាក់បញ្ចូលទៅក្នុងការបង្កើតយុទ្ធសាស្ត្រ និងកម្មវិធី
- ដាក់បញ្ចូលបទអន្តរាគមន៍ចាំបាច់សម្រាប់យុវជនងាយរងគ្រោះទៅក្នុងគោលនយោបាយ និងផែនការថ្នាក់ជាតិ និងក្រោមជាតិ និងជាពិសេស NSPIV និងគំរូប្រើប្រាស់ថវិកាថ្មី (New Funding Model)
- ជំរុញឱ្យមានផ្តោតលើបញ្ហារបស់យុវជនងាយរងគ្រោះ និងបំពេញលើអន្តរាគមន៍ដែលមានស្រាប់

ក្រុមគោលដៅសំខាន់ៗ ដែលត្រូវដាក់បញ្ចូលទៅក្នុងឯកសារនេះ រួមមាន យុវជនបុរសស្រឡាញ់បុរស យុវជនភ្លែងភេទ យុវជនបម្រើការកន្លែងកម្សាន្តសប្បាយ យុវជនប្រើប្រាស់គ្រឿងញៀន និងយុវជនរស់នៅជាមួយមេរោគអេដស៍។

*៣. ដំណើរការចងក្រងឯកសារ:* ឯកសារគោលនេះ ត្រូវបានរៀបចំឡើងតាមដំណាក់កាល និងវិធីសាស្ត្រដូចជា:

- រៀបចំពិនិត្យទៅលើឯកសារដែលមានស្រាប់
- សម្ភាសន៍ជាមួយជនបង្គោល រួមទាំងអ្នកពាក់ព័ន្ធ

- រៀបចំកិច្ចប្រជុំពិភាក្សាជាមួយក្រុម Technical Youth Task Force
- រៀបចំកិច្ចពិភាក្សាជាមួយយុវជនងាយរងគ្រោះ (ថ្នាក់ជាតិ និងក្រោមជាតិ)
- រៀបចំសេចក្តីព្រៀងនៃឯកសារគោល និងប្រជុំជាមួយអ្នកពាក់ព័ន្ធ ដើម្បីអនុម័ត

៤. ***វគ្គបណ្តុះបណ្តាលស្តីពីភាពជាអ្នកដឹកនាំសម្រាប់យុវជនងាយរងគ្រោះដោយសារមេរោគអេដស៍ (ជំនួយថវិកា UNESCO)*** ៖ វគ្គនេះមានគោលបំណង ក្នុងការ កសាងសមត្ថភាពដល់យុវជនងាយរងគ្រោះ (ដូចជាYouth Activist and Advocates) ក្នុងដំណើរការដឹកនាំបទអន្តរាគមន៍បង្ការមេរោគអេដស៍នៅកម្ពុជា។ វគ្គនេះ មានរយៈពេល៥ថ្ងៃ ដែលផ្តោតលើប្រធានបទសំខាន់ៗដូចជាៈ

- ***ថ្ងៃទី១:*** ការស្វែងយល់ពីស្ថានភាពរបស់យុវជនងាយរងគ្រោះដោយសារជំងឺអេដស៍
- ***ថ្ងៃទី២:*** ចំណុចខ្លាំងរបស់ភាពជាអ្នកដឹកនាំ
- ***ថ្ងៃទី៣:*** សុភាពបន្តពូជ សុខភាពផ្លូវភេទ និងការពិគ្រោះយោបល់
- ***ថ្ងៃទី៤:***ភាពជាអ្នកដឹកនាំ និងការតស៊ូមតិ
- ***ថ្ងៃទី៥:***ភាពជាអ្នកដឹកនាំ និងការផ្លាស់ប្តូរ

*៥.* ផែនការបន្ទាប់ៈ

- រៀបចំកិច្ចពិគ្រោះយោបល់នៅភ្នំពេញថ្ងៃទី ២៦ មិថុនា ២០១៤ (លើកពេលទៅខែកក្កដា)
- រៀបចំកិច្ចពិភាក្សាលំអិតជាមួយក្រុមគោលដៅថ្ងៃទី ២៧ មិថុនា ២០១៤ នៅបាត់ដំបង
- រៀបចំទំនាក់ទំនងជាមួយសមាគមន៍យុវជនជាតិកម្ពុជា ដើម្បីបញ្ជ្រៀបការងារមេរោគអេដស៍ និងជំងឺអេដស៍។